# ដោយសារស្រលាញ់ការសិក្សាជំរុញឲ្យកម្មការិនីរោងចក្រ...

តមកពីទំព័រ១

ភក្តិ និងក្រុមគ្រួសាររិះគន់ ឬ បន្ទច់បង្អាក់ដល់ការសិក្សារបស់នាងក្តី ក៏នាងមិនដែលគិតនឹងបោះបង់វាចោលឡើយ។

មិនខុសពី សុត ផង នោះទេ ជ័យ អាន់ បេក្ខនារីដែលបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិមួយរូបទៀត ហើយជាកម្មការិនីរោងចក្រដែរនោះបានឲ្យដឹងថា នាងពិតជារំភើបខ្លាំងណាស់ ដែលអាចធ្វើឲ្យក្តីស្រមៃរបស់ខ្លួនបានក្លាយជាការពិត។ នាងថា «ក្តីស្រមៃរបស់ខ្ញុំ គឺប្រឡងជាប់បាក់ឌុប ពីមុនខ្ញុំមិនដឹងថា ខ្ញុំចង់ធ្វើអីទេ ខ្ញុំដឹងត្រឹមថាខ្ញុំត្រូវរៀន ឲ្យបានចប់ថ្នាក់ទី១២ ប៉ុន្តែម្តាយខ្ញុំគាត់ថា កូនស្រីរៀនច្រើនអត់ល្អទេ ចឹងខ្ញុំត្រូវឈប់រៀនថ្នាក់ទី៩ ហើយពេលខ្ញុំដាក់ពាក្យប្រឡងហ្នឹង គ្រួសារខ្ញុំក៏មិនសូវគាំទ្រដែរ បើអ្នកធ្វើការជាមួយវិញ គេសើចយំយើងថា មិនដឹងខំប្រឡងធ្វើអី... ប៉ុន្តែពេលនេះក្តីស្រមៃរបស់ខ្ញុំក្លាយជាការពិតហើយ»។

ដើម្បីសម្រេចគោលដៅរបស់ខ្លួនមនុស្សម្នាក់ៗរមែងត្រូវការកម្លាំងចិត្តនឹងការជាគាំទ្រជាចាំបាច់។ កម្មការិនីទាំងពីរនាក់បានឲ្យដឹងថា ពួកនាងអាចសម្រេចជោគជ័យនេះបាន គឺដោយសារតែមានការគាំទ្រ និងណែនាំពីសមាគមមណ្ឌលព័ត៌-មានកម្មករ ក៏ដូចជាកម្លាំងចិត្តពីខ្លួនឯងក្នុងការជម្នះនូវឧបសគ្គទាំងឡាយ។

សមាគមមណ្ឌលព័ត៌មានកម្មករ បានផ្តល់កន្លែងសុវត្ថិភាពទៅដល់កម្មកា-រិនីកម្មកររោងចក្រ ដែលពួកគេអាចស្វែងយល់ពីសិទ្ធិរបស់ពួកគេដើម្បីធានាបាននូវលក្ខខណ្ឌការងារ និងការរស់នៅល្អប្រសើរឡើង កសាងសមត្ថភាពក្នុងការគិត និងវិភាគអំពីបញ្ហារួមរបស់កម្មករ។ ជាពិសេស សមាគមក៏មានផ្តល់ថ្នាក់បង្រៀនភាសាខ្មែរ និងភាសាអង់គ្លេសទៅដល់កម្មការិនី-កម្មករដើម្បីឲ្យពួកគេអាចសរសេរ និងអានបានតាមរយៈមណ្ឌលសំចតទាំង ៦ របស់ខ្លួនគឺ មណ្ឌលសំចត ជម្លូវែន ព្រៃទា ពោធិ៍សែនជ័យ ទឹកថ្លា ចាក់អង្រែក្រោម និងទួលសង្កែ។

ភាពជោគជ័យរមែងមិនកើតឡើងចំពោះបុគ្គលណាដែលខ្វះការខិតខំប្រឹងប្រែង និងឆាប់ចុះចាញ់នោះទេ។ ការបែងចែកពេលវេលាបំពេញតួនាទីជាកូនល្អដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ និងពេលវេលាសម្រាប់ការរៀនសូត្រគឺជារឿងលំបាកមួយ ហើយវាអាចនឹងបរាជ័យ ប្រសិនបើបុគ្គលម្នាក់ៗខ្វះភាពអំណត់។ កម្មការិនីវ័យ ២៣ឆ្នាំ សុត ផង បាននិយាយថា « វាលំបាក ពេលខ្លះខ្ញុំចង់តែបោះបង់ចោលក្តីស្រមៃនេះ ...ដោយសារខ្ញុំអត់ពេលដូចគេ ចឹងខ្ញុំត្រូវចេះបែងចែកម៉ោងរៀន គឺខ្ញុំអានមេរៀន ហើយថតសំឡេងទុក ពេលធ្វើការបណ្តើរ ខ្ញុំស្តាប់បណ្តើរ ហើយពេលសម្រាកញ៉ាំបាយ ខ្ញុំក៏យកមេរៀនមកមើល ហើយថ្ងៃអាទិត្យខ្ញុំទៅរៀននៅសាលា»។

ចំណែកវិធីសាស្ត្រក្នុងការសិក្សារហូតទទួលបានជោគជ័យរបស់កម្មការិនីវ័យ ៣០ឆ្នាំ ជ័យ អាន់ វិញ គឺមួយថ្ងៃនាងគេងតែ ៤ ទៅ ៥ម៉ោងប៉ុណ្ណោះ ពោលគឺពេលយប់ នាងមើលមេរៀនរហូតដល់ម៉ោង ១១ យប់ ហើយនាងរំឭកមេរៀនម្តងទៀតនៅម៉ោង ៤ទៀបភ្លឺ។

បេក្ខនារីដែលបានប្រឡងជាប់បាក់ឌុបទាំងពីររូបនេះបានផ្តាំផ្ញើដល់កម្មការិនី-កម្មករដទៃទៀតដែលមានក្តីស្រមៃចង់បន្តការសិក្សា សូមចាប់ផ្តើមធ្វើវាឡើង ព្រោះការរៀនសូត្រមិនចេះហួសពេលនោះទេ វាមិនសំខាន់លើអាយុឡើយ។ អ្នកទាំងពីរថា មានតែការសិក្សាទេទើបអាចជួយឲ្យជីវិតរួចផុតពីការជិះជាន់គាបសង្កត់។

ជាលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់កម្មការិនីទាំងពីរនាក់នេះ បច្ចុប្បន្ន សុត ផង កំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រឆ្នាំទីមួយ ផ្នែកច្បាប់នៅសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប។ ចំណែក ជ័យ អាន់ កំពុងរៀនឆ្នាំទីមួយនៅសាកលវិទ្យាល័យអាយអាយស៊ីផ្នែករដ្ឋបាលសាធារណៈ។

ក្រោមការគាំទ្ររបស់សមាគមមណ្ឌលព័ត៌មានកម្មករតាមរយៈមណ្ឌលសំចតទាំង ៦ កម្មការិនីរោងចក្រកាត់ដេរ កាលពី ឆ្នាំ ២០១៥ បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន ៨នាក់៕


កម្មការិនីរោងចក្រ ជ័យ អាន់

បោះពុម្ពផ្សាយដោយ

អាសយដ្ឋាន: ផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទូរស័ព្ទ: ០១៧ ២២៩ ៥០០
អ៊ីមែល: communication.wic@gmail.com
គេហទំព័រ: www.wic.unitedsisterhood.org





ទពរកម្មករ
ឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ វីរភាពគួរចងចាំ



# ដោយសារស្រលាញ់ការសិក្សាជំរុញឲ្យកម្មការិនីរោងចក្រប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ

ទោះបីស្ថិតនៅក្នុងស្ថានភាពលំបាកក្តី ដោយសារការស្រលាញ់ការសិក្សាបានជំរុញឲ្យកម្មការិនីកាត់ដេរ សម្រេចចិត្តឆ្លៀតពេលទំនេរពីការងារដើម្បីរៀនរហូតបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ។

ក្នុងចំណោមបេក្ខជនប្រឡងសញ្ញា-បត្រមធ្យមសិក្សាទុតិយភូមិសរុបចំនួន ៨៣.៣២៥ នាក់ កាលពីឆ្នាំ ២០១៥ មានបេក្ខជនប្រឡងជាប់ចំនួន ៤៦.៥៦០ នាក់ ដែលស្មើនឹង ៥៥,៨៨% នៃបេក្ខជនសរុប។ ក្នុងចំណោមបេក្ខជនប្រឡងជាប់ជិត ៦០% នោះ ក៏មានកម្មការិនីរោងចក្រផងដែរ។

នេះគឺជាមោទនភាពមួយសម្រាប់កម្មការិនីរោងចក្រដែលអាចប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ។ សុត ផង ជាកម្មការិនីមួយរូបដែលមានសមត្ថភាពយកបានសញ្ញាបត្រមួយនេះបានបង្ហាញនូវអារម្មណ៍ត្រេកអរយ៉ាងខ្លាំងដែលខ្លួនអាចធ្វើបាន។ នាងថា ការសិក្សាជាអ្វីដែលនាងស្រលាញ់ខ្លាំងបំផុត ទោះបីមិត្ត

តទៅទំព័រ៤


កម្មការិនីរោងចក្រ សុត ផង


កម្មកររោងចក្រអឹមវ៉េចេញពីធ្វើការ

# ហេតុអ្វីកម្មករមិនត្រូវទទួលប្រាក់ឈ្នួល ៥០ភាគរយនៅពេលរោងចក្រមិនមានការងារធ្វើពេញលេញ?

កម្មកររោងចក្រ អឹមវ៉េ អន្តរជាតិ សាខាទី៣ កាលពីថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៦ ទទួលបានសំណងពេញលេញសម្រាប់ការឈប់សម្រាកទទួលបានប្រាក់ឈ្នួល ៥០ ភាគរយ។

បន្ទាប់ពីរោងចក្រអះអាងថាមិនមានការងារធ្វើពេញលេញ កម្មកររោងចក្រ អឹមវ៉េនេះត្រូវឈប់សម្រាក ទទួលប្រាក់ឈ្នួលគោល ៥០ភាគរយ និងការព្យួរការងារ ចាប់ពីដើមឆ្នាំ ២០១៥ រហូតមកដល់ខែមីនា ឆ្នាំ ២០១៦។

កម្មការិនីវ័យ៤០ឆ្នាំ ងួន សំណាង ដែលមានអតីតភាពការងារក្នុងរោងចក្រខាងលើនេះជិត ២០ ឆ្នាំ បានរៀបរាប់ឲ្យដឹងថាស្ថានភាពមិនមានការងារធ្វើគ្រប់គ្រាន់នេះបានចាប់ផ្តើមតាំងពីដើមឆ្នាំ ២០១៥ ដោយមុនដំបូង រោងចក្រឲ្យធ្វើការ ៤ថ្ងៃ ឈប់សម្រាកទទួលប្រាក់ឈ្នួល

តទៅទំព័រ៣

# ភាពជោគជ័យនៃយុទ្ធនាការផ្ទះជួល

ស្របពេលដែលព័ត៌មានអំពីប្រាក់ឈ្នួលគោលកម្មករកើនឡើង នៅដើមឆ្នាំ ២០១៦ ម្ចាស់ផ្ទះជួលមួយចំនួនបានបង្ហើបព័ត៌មានពីការដំឡើងថ្លៃបន្ទប់ជួលរបស់ខ្លួន ដែលជាហេតុធ្វើឲ្យកម្មការិនីកម្មករមួយចំនួនមានការមិនពេញចិត្ត។

តំណាងរបស់កម្មការិនី-កម្មករនៅបន្ទប់ជួលតំបន់ជម្លូវែន កម្មការិនី ឌុក សម្បត្តិ អាយុ ២៦ឆ្នាំ បានឲ្យដឹងថា នៅចុងឆ្នាំ ២០១៥ ក្រោយពីអគ្គិសនីកម្ពុជាបានតបណ្តាញចូលតាមបន្ទប់ជួលនីមួយៗ ម្ចាស់បន្ទប់ជួលមិនព្រមឲ្យវិក័យប័ត្រអគ្គិសនីមកអ្នកជួលឡើយ។ មិនត្រឹមតែប៉ុណ្ណោះ ម្ចាស់បន្ទប់ជួលមិនអនុញ្ញាតឲ្យ

តទៅទំព័រ២

# ភាពជោគជ័យនៃយុទ្ធនាការផ្ទះជួល



សកម្មភាពពិភាក្សាលើបញ្ហាផ្ទះជួលឡើងថ្លៃ

តមកពីទំព័រ១

អ្នកជួលបង់ថ្លៃ ភ្លើងតាមរឹងដែលគិតថ្លៃសេវា១០០០ រៀលឡើយ ដោយគាត់តម្រូវឲ្យអ្នកជួលបង់ថ្លៃភ្លើងជាមួយគាត់ ហើយគាត់គិតថ្លៃ សេវា២០០០រៀល។

លើសពីនេះទៀត នាងថា ម្ចាស់បន្ទប់ជួលបានប្រាប់អ្នកជួលថានឹងដំឡើងថ្លៃបន្ទប់៣ដុល្លារ ដោយហេតុផលថាប្រាក់ឈ្នួលកម្មករនឹងកើនឡើង។ សម្បត្តិបន្តថា «ប្រាក់ឈ្នួលកើនឡើង ប៉ុន្តែលក្ខខណ្ឌការងារពួកខ្ញុំពិបាកជាងមុន ពួកខ្ញុំត្រូវបង្ខំឲ្យធ្វើការច្រើនជាងមុនរកតែពេលសម្រាកដៃមិនបានផង។ ពីមុនគេ (រោងចក្រ) ឲ្យដេរអាវ ៥០០(អាវ) ថែមម៉ោងដល់ម៉ោង ៦ល្ងាច ដល់ប្រាក់ខែឡើង គេឲ្យដេរដល់ ៦០០អាវ ត្រឹមម៉ោង ៤ល្ងាច ហើយបើធ្វើអត់បានទេគេព្រមានពីរទៅបីដង ហើយបើអត់បានទៀតគេបញ្ឈប់តែម្តង»។

ស្របជាមួយគ្នានេះដែរ តំណាងកម្មករមួយរូបទៀត ដែលធ្វើការតវ៉ាចំពោះថ្លៃផ្ទះជួលនេះដែរ លន់ វុទ្ធី អាយុ ២៨ឆ្នាំ បានឲ្យដឹងថា ថ្វីត្បិតតែប្រាក់ឈ្នួលគោលកើនឡើង ប៉ុន្តែទំនិញនៅលើទីផ្សារក៏មានការឡើងថ្លៃផងដែរ។ លោកថា ត្រី សាច់ បន្លែសុទ្ធតែឡើងថ្លៃ ដូច្នេះប្រសិនបើម្ចាស់បន្ទប់ជួលដំឡើងថ្លៃបន្ទប់ ខណៈដែលបន្ទប់របស់គាត់នៅតែមានស្ថានភាពដដែល (បន្ទប់លិច ទឹកនៅពេលភ្លៀងធ្លាក់) គឺជារឿងមួយមិនត្រឹមត្រូវនោះទេ។

ប្រាក់ឈ្នួលគោលកម្មករត្រូវកើនឡើងពីចំនួន១២៨ដុល្លារក្នុងមួយខែនៅឆ្នាំ ២០១៥ ដល់ ១៤០ដុល្លារ ក្នុងមួយខែនៅឆ្នាំ ២០១៦។

ដោយសារតែមិនអាចទទួលយកការដំឡើងថ្លៃនេះ សម្បត្តិថា នាង និងកម្មករមួយចំនួនទៀតបានពិភាក្សាគ្នា និងសម្រេចចិត្តស្នើសុំសមាគមមណ្ឌលព័ត៌មានកម្មករឲ្យជួយប្រឹក្សាយោបល់។ នាងថា មណ្ឌលសំចតជម្លូវនៃបានជួយសម្របសម្រួលពីបញ្ហាដែលកើតមានឡើង ក៏ដូចជាជួយផ្តល់ជាគំនិតក្នុងការចរចា និងលើកទឹកចិត្តដល់កម្មករក្នុងការដោះស្រាយបញ្ហានេះ។

អ្នកសម្របសម្រួលមណ្ឌលសំចតជម្លូវនៃ កញ្ញា លឹម ស្រីមុំ បានប្រាប់ថា មូលហេតុដែលមណ្ឌលជួយផ្តល់ការប្រឹក្សាយោបល់ក៏ដូចជាផ្តល់កន្លែងសម្រាប់កម្មករពិភាក្សាគ្នា ព្រោះមណ្ឌលមើលឃើញថា ការដំឡើងថ្លៃឈ្នួលបន្ទប់ និងប្រាក់ចំណូលដែលកម្មករទទួលបានមិនស៊ីគ្នាទេ។ ស្រីមុំបន្តថា «យើងវិភាគលើស្ថានភាពរស់នៅរបស់ពួកគាត់ និងស្ថានភាពបន្ទប់ជួលរបស់ពួកគាត់ ... បន្ទប់តូច ដំបូលលេច ភ្លៀងហូរចូល បើបន្ទប់ទឹកវិញមានតែ៤ហើយត្រូវប្រើរួមគ្នាជាង១០០នាក់ តើស្ថានភាពបែបនេះស័ក្តិសមនឹងការដំឡើងថ្លៃ (បន្ទប់) ឬទេ?»

ក្រោយពីបានការជួយជ្រោមជ្រែងពីសមាគមមណ្ឌលព័ត៌មានកម្មករ និងការចុះចងក្រងជាបន្តបន្ទាប់ តំណាងកម្មករបានប្រមូលស្នាមមេដៃចំនួន ៤១ស្នាមមេដៃ។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦ តំណាងកម្មករបានជួបចរចាជាមួយម្ចាស់បន្ទប់ជួលដើម្បីស្នើសុំពិភាក្សាពីបញ្ហាមួយចំនួនដែលកំពុងកើតមាននៅក្នុងបន្ទប់ជួល។ នាងថា កម្មករបានដាក់សំណើចំនួន៤ ដល់ម្ចាស់បន្ទប់ជួលគឺ ទីមួយចេញវិក័យប័ត្រភ្លើង ហើយអ្នកជួលអាចបង់នៅទីណាក៏បាន ទីពីរស្នើឲ្យបើកទ្វារបន្ទប់ទឹកទាំង ៤ ដែលតែងតែបិទចំនួនពីរបន្ទប់នៅពេលថ្ងៃ ព្រមទាំងឈប់យកលុយថ្លៃបន្ទប់ទឹកពីអ្នកស្នាក់នៅ និងបងប្អូនពេលមកលេងម្តងម្កាល ទីបី ស្នើឲ្យមានការជួសជុលដំបូលធ្លុះធ្លាយ និងដាក់គម្របលូស៊ីម៉ង់ត៍ និងទីបួន ស្នើឲ្យមានការរៀបការ៉ូចំពោះបន្ទប់ណាដែលមិនទាន់មាន។ ជាលទ្ធផលនាងថា ម្ចាស់បន្ទប់ជួលបានយល់ព្រមចំពោះចំណុចទីមួយ និងចំណុចទីពីរ ហើយម្ចាស់បន្ទប់ជួលក៏សន្យាថាមិនដំឡើងថ្លៃបន្ទប់ដរាបណាបន្ទប់ទាំងនោះមិនទាន់ជួសជុលឲ្យបានស្អាត។

សម្បត្តិ និងវុទ្ធីបានស្នើឲ្យកម្មការិនីកម្មករ ក៏ដូចជាអ្នកជួលបន្ទប់ទាំងអស់ឲ្យចេះសាមគ្គី និងពិភាក្សាគ្នាចំពោះបញ្ហាដែលកើតមានឡើង។ តំណាងទាំងពីរក៏បានផ្តាំផ្ញើ កុំឲ្យកម្មករទាំងអស់ចាញ់ការគំរាមកំហែងម្ចាស់ផ្ទះ ឬបន្ទប់ជួល ហើយត្រូវចេះរួមគ្នារកដំណោះស្រាយ ព្រោះរាល់បញ្ហាសុទ្ធតែមានដំណោះស្រាយ។

ដោយមានការសម្របសម្រួលពីសមាគមមណ្ឌលព័ត៌មានកម្មករ យុទ្ធនាការផ្ទះជួលមិនត្រឹមតែជោគជ័យនៅតំបន់ជម្លូវនៃនោះទេ យុទ្ធនាការនេះក៏ធ្វើឡើងប្រកបដោយជោគជ័យនៅតាមតំបន់ផ្សេងៗទៀតផងដែរ ដូចជា តំបន់ទឹកថ្លា និងទួលសង្កែជាដើម៕





# ហេតុអ្វីកម្មករមិនត្រូវទទួលប្រាក់ឈ្នួល ៥០ភាគរយ...



កម្មកររោងចក្រអឹមវ៉េចេញពីធ្វើការ

តមកពីទំព័រ១

គោល ៥០% ៣ថ្ងៃ។ លុះក្រោយមកស្ថានភាពការងារកាន់តែដុនដាបឡើង ដោយធ្វើការ ១សប្តាហ៍ឈប់សម្រាក ២សប្តាហ៍។ ក្រៅពីជួបនឹងបញ្ហាមិនមានការងារធ្វើពេញលេញទទួលប្រាក់ឈ្នួល ៥០ភាគរយ កម្មការិនី-កម្មកររោងចក្រអឹមវ៉េ សាខាទី ៣ ក៏បានជួបនឹងបញ្ហាព្យួរការងារផងដែរ។ រាល់ការព្យួរការងារកម្មការិនី-កម្មករ រោងចក្រនេះទទួលបានប្រាក់ឈ្នួលត្រឹមតែ៥០ដុល្លារប៉ុណ្ណោះក្នុងមួយខែ។ ស្ថានភាពទាំងនេះធ្វើឲ្យកម្មការិនី-កម្មករមានបញ្ហាប្រឈមខ្វះខាតក្នុងជីវភាពប្រចាំថ្ងៃ កូនចៅបោះបង់ការសិក្សា ជំពាក់បំណុល និងត្រូវឆ្លៀតទៅរកការងារផ្សេងៗធ្វើបន្ថែម។ ដោយសារកម្មកររោងចក្រភាគច្រើនជាជនចំណាកស្រុកមកពីតាមបណ្តាខេត្ត ពួកគេមានបន្ទុករកចំណូលផ្គត់ផ្គង់គ្រួសារ ប៉ុន្តែនៅពេលដែលស្ថានភាពការងារផ្លាស់ប្តូរធ្វើឲ្យស្ថានភាពរស់នៅរបស់ពួកគេប្រឈមនឹងបញ្ហាជាច្រើន។ លោក តុល ធី អាយុ៣៥ឆ្នាំ មកពីខេត្តកំពង់ចាមបានឲ្យដឹងថា លោកជាមេគ្រួសារដែលត្រូវទទួលបន្ទុកចិញ្ចឹមប្រពន្ធ ដែលកំពុងមានជំងឺ និងកូនពីរនាក់។ កម្មករផ្នែកផុង រូបនេះបន្តថា នៅពេលគ្មានការងារធ្វើពេញលេញ លោកត្រូវខ្ចីប្រាក់ពីធនាគារដើម្បីផ្គត់ផ្គង់គ្រួសារ និងព្យាបាលជំងឺភរិយារបស់លោក។

ដោយសារមិនអាចទ្រាំទ្រនឹងស្ថានភាពមិនមានការងារធ្វើពេញលេញបានកម្មការិនី-កម្មករ រោងចក្រ អឹមវ៉េ សាខាទី៣ នៅខែមករា ឆ្នាំ ២០១៦ បាននាំគ្នាមួយក្រុមតូចសុំសមាគមមណ្ឌលព័ត៌មានកម្មករ (មពក) ឲ្យជួយដោះស្រាយលើបញ្ហាដែលរោងចក្រនេះមិនមានការងារធ្វើ ហើយបានបន្តផ្តល់ប្រាក់ឈ្នួល៥០ភាគរយ ដល់កម្មកររហូតមក។ មពក បានយល់ព្រមសម្របសម្រួលផ្តល់បច្ចេកទេស និងធ្វើការរួមគ្នាជាមួយកម្មការិនី-កម្មករនៅគ្រប់ដំណើរការទាំងអស់។

មពក និងកម្មករដែលជាតំណាងបានបន្តប្រមូលព័ត៌មាន និងឯកសារពាក់-ព័ន្ធផ្សេងៗ ហើយកម្មករខ្លះក៏បានសួរទៅកាន់តំណាងសហជីពពីបញ្ហាមិនមានការងារធ្វើនេះ តែត្រូវបានតំណាងសហជីពប្រាប់ ថាឲ្យទៅជួបម្ចាស់ផ្លាកទៅបានដឹងហើយ។ នៅក្នុងរោងចក្រ ស៊ិន ពិសីបានបញ្ជាក់ថា «ឥឡូវយើងអត់ធ្វើកូដកម្មទេ យើងព្យាយាមជជែកជាមួយខាងរោងចក្រដើម្បីឲ្យគេផ្តល់ការងារឲ្យធ្វើ គេសន្យាថា នៅខែ៤ខាងមុខមានការងារឲ្យធ្វើ ប៉ុន្តែជាក់ស្តែងនៅខែកុម្ភៈនេះគេបានបិទជាន់ទី៣ និងជាន់ទី៤អត់ឲ្យពួកយើងចូលជាន់នោះទេ ហើយពួកយើងអត់ព្រមទៅផ្ទះវិញទេ ពួកយើងក្រាលតង់ ក្រាលក្រដាសកាតុង នៅទីធ្លារោងចក្រ»។ មានការជជែកពិភាក្សាគ្នាជាច្រើនលើកច្រើនសារពីស្ថានភាព ព័ត៌មាន និងឯកសារពាក់ព័ន្ធ ព្រមទាំងមានការចុះត្រួតពិនិត្យតាមទីតាំងមួយចំនួនដែលទាក់ទងនឹងសង្វាក់ផលិតកម្ម។ ក្រោយមកមានការប្រជុំ កំណត់អ្នកពាក់ព័ន្ធ មពក បានទំនាក់ទំនងជាមួយម្ចាស់ផ្លាកសុំការជួបពិភាក្សាដោយមានតំណាងកម្មករមកជាមួយ ដើម្បីជជែកពីស្ថានភាពដែលកើតមានឡើងក្នុងរោងចក្រ។

ក្រោយពីមានការចុះអន្តរាគមន៍ពីអ្នកពាក់ព័ន្ធ នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ខាងរោងចក្រអឹមវ៉េ អន្តរជាតិ សាខាទី៣ បានចេញសេចក្តីជូនដំណឹងដល់កម្មករទាំងអស់ថា «ក្រុមហ៊ុនសម្រេចផ្តល់ប្រាក់ប្រាក់ឈ្នួលគោល ១០០% តាមចំនួនថ្ងៃដែលកម្មករគ្មានការងារធ្វើជាក់ស្តែង»។ ការផ្តល់សំណងនេះអនុវត្តពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៦។ កម្មករសរុបដែលបានទទួលប្រាក់សំណងមានប្រមាណ ២០០០នាក់ ដោយពួកគេទទួលបានសំណងម្នាក់ៗចន្លោះពី ៥០ដុល្លារ ដល់ ១៩០ដុល្លារ។ លើកលែងតែករណីព្យួរការងារពួកគេមិនដោះស្រាយឲ្យនោះទេ។

សូមមើលបន្ថែម ច្បាប់ការងារ មាត្រា ៨៣ កំណត់ពីកំហុសរបស់និយោជក (វាក្យខណ្ឌ ១ និង ៥) មាត្រា ១០៤ កំណត់ពីប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា មាត្រា ១០៥ កំណត់ពីមោឃភាពកិច្ចសន្យាដែលអត្រាទាបជាងប្រាក់ឈ្នួលអប្បបរមា៕